**សំណួរ**

**អ្វីទៅជាការលើកយកបទបញ្ញត្តិសន្ធិសញ្ញា មកសំអាង** (Invocation)?

**ចម្លើយ**

តាមទ្រឹស្តី និងការអនុវត្តរបស់រដ្ឋ ក្រោយពេលសន្ធិសញ្ញា ចូលជាធរមាន ក្នុងប្រទេសខ្លះ បុគ្គលដែលជាម្ចាស់សិទ្ធិ និងភាគីពាក់ព័ន្ធ មិនទាន់ត្រូវបានអនុញ្ញាតឲ្យលើកបទបញ្ញត្តិណាមួយ មកសំអាង ឬថាបំពាននៅមុខអាជ្ញាធរ ជាពិសេស តុលាការទេ។ នេះដោយសារ វាមិនទាន់មានច្បាប់ជាមូលដ្ឋាន ឬមិនបានបំពេញលក្ខខ័ណ្ឌផ្សេងៗទៀត ដែលរដ្ឋនីមួយៗតម្រូវ។ អ្វីទៅជាការលើកយកបទបញ្ញត្តិសន្ធិសញ្ញាមកសំអាង (Invocation)?

Invocation ជាការលើកបទបញ្ញត្តិណាមួយនៃសន្ធិសញ្ញាដែលរដ្ឋជាភាគី មកសំអាង ឬថាបំពាននៅមុខអាជ្ញាធរ ឬតុលាការ។ គ្មានវិធានអន្តរជាតិណាមួយ ចែងជាក់លាក់អំពី Invocation ទេ។ អ្វីជាចម្លើយ ដ៏ងាយស្រួលគឺ គេអាចលើកមកសំអាងបានភ្លាម ប្រសិនបើ ភាគីដែលអាចរួមមានរដ្ឋជាភាគីដែលបុគ្គលកំពុងចោទថា បានបំពានកាតព្វកិច្ច ឯកភាពក្នុងសន្ធិសញ្ញាថា ជាសន្ធិសញ្ញាអនុវត្តបានជាស្វ័យប្រវត្តិ (Self-Executing Treaty) ដូចនេះភាគីអាចលើកយកមកសំអាងបានហើយ។ រដ្ឋខ្លះ ទាមទារថា លុះត្រា សន្ធិសញ្ញា ដែលពាក់ព័ន្ធ មានបទបញ្ញត្តិ ចែងផ្តល់នូវសិទ្ធិដាក់ពាក្យបណ្តឹង (Right to Litigation) ទើបអាចប្តឹង និងលើកយកមកសំអាងបាន។ រដ្ឋខ្លះ ដូចជាបារាំង បន្ថែមពីលើ ការចូលជាធរមាន សន្ធិសញ្ញា ដែលបារាំងជាភាគី ត្រូវបកប្រែជាភាសាជាតិ (បារាំង) ហើយចុះក្នុងទស្សនាវដ្តីផ្លូវការ (Official Gazette) ក្រោយពេលនេះ ទើបភាគីអាចលើយកបញ្ញត្តិមកចោទឆ្លើយបាន។

ផ្អែកតាមការបង្ហាញក្នុងកថាខ័ណ្ឌខាងលើ វាហាក់ដូចជា ការអនុវត្តច្បាប់អន្តរជាតិ គ្មានលក្ខណៈស៊ីសង្វាក់គ្នា ហើយការផ្តល់ប្រសិទ្ធភាពដល់វិធានអន្តរជាតិ ដូចជាស្ថិតនៅក្នុងកណ្តាប់ដៃរបស់រដ្ឋ។ ឧទាហរណ៍ ក្នុងករណី ប្រសិនបើសន្ធិសញ្ញា មិនទាន់ត្រូវបានបកប្រែ និងផ្សាយជាផ្លូវការ បុគ្គលនឹងមិនអាចលើកមកសំអាងបានទេ។ គេអាចអះអាងថា កាតព្វកិច្ចនៃសន្ធិសញ្ញា គឺនៅតែក្នុងក្រដាស។

សម្រាប់កម្ពុជា ទាំងច្បាប់ និង សាលក្រម មិនបានបំភ្លឺបញ្ហានេះទេ។ អាស្រ័យហេតុនេះ វាគួរតែជាប្រធានបទស្រាវជ្រាវសម្រាប់ អ្នកសិក្សា ឬស្រាវជ្រាវ ច្បាប់អន្តរជាតិ ក្នុងប្រទេសកម្ពុជានាពេលខាងមុខ។

**Further Readings**: XUE Hanqin and JIN Qian, *International Treaties In the Chinese Domestic Legal System*, Chinese Journal of International Law (2009), Vol. 8, No. 2, 299–322 doi:10.1093/chinesejil/jmp007; Christian Dominice, *the international responsibility of States for Breach of Multilateral Obligations*, 10 (2) European Journal of International Law, 1999, 353-363; David Sloss, *Domestic Application of Treaties* (2011), Available at: http://digitalcommons.law.scu.edu/facpubs/635.